ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តតាកែវ

សំណុំរឿងរដ្ឋប្បវេណីលេខ ៧៨ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១
សាលក្រមលេខ ២០(ក)ចុះថ្ងៃ ទី២៧ ខែឧសភា ឆ្នាំ២០២១

បង្កើតឡើងតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកត/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។ បានបើក និងបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង៨ព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រម**

ឯកឧត្តម [redacted] ប្រធាន និងជាចៅក្រមនៃសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តតាកែវ

រវាងដើមចោទឈ្មោះ [redacted] ម៉ាឡា ភេទស្រី អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ មានអាសយដ្ឋានបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] ផុន(ស) ម្ដាយឈ្មោះ [redacted] សាខន (រ) ប្ដីឈ្មោះ [redacted] ដុក មានកូន ០៣នាក់ ។

ដោយមានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

ចុងចម្លើយឈ្មោះ [redacted] ដុក ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរ ប៉ូលីសពន្ធនាគារ មានអាសយដ្ឋានបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] សាមិ (ស្លាប់) ម្ដាយឈ្មោះ [redacted] វ៉ាន្នី(រស់) ប្រពន្ធឈ្មោះ [redacted] ម៉ាឡា មានកូន ០៣នាក់ ។

**១-ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ៖**

ក.សុំលែងលះពីប្ដីឈ្មោះ [redacted] ដុក

ខ.សុំសិទ្ធិគ្រប់គ្រងកូន ០៣នាក់

គ.ទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ចំនួន ៥០០.០០០រៀល ក្នុង ០១ខែ

ឃ.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ

**២-អង្គហេតុសង្ខេប៖**

តាមពាក្យបណ្ដឹង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ របស់លោកស្រី [redacted] ម៉ាឡា ជាដើមចោទ បានបញ្ជាក់ថា ខ្លួនបានរៀបការជាមួយចុងចម្លើយ កាលពីអំឡុងឆ្នាំ១៩៩១ និង បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ក្នុងអំឡុងឆ្នាំ ១៩៩១ ។ អំឡុងពេលរួមរស់ជាមួយគ្នា មានកូនបីនាក់គឺ១.ឈ្មោះ [redacted] ម៉ាលីន ភេទស្រី កើតនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៦, កូនទី២ឈ្មោះ [redacted] ម៉ាលីស ភេទស្រី កើតនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ , កូនទី៣.ឈ្មោះ [redacted] ដាវ៉ុង ភេទស្រី កើតនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៤ និងពុំមានទ្រព្យសម្បត្តិរួម និង បំណុលរួមឡើយ ។ ការរស់នៅចេះតែមិនចុះសម្រុងគ្នា ដោយសារតែប្ដីរបស់



Scanned with CamScanner

ខ្លួនផិតក្បត់មានស្រីកំណាន់ បានចុះចោលខ្លួននិងកូន មិនផ្តល់ប្រាក់សម្រាប់ផ្គត់ផ្គង់គ្រួសារ និងពុំដែលសួរសុខទុក្ខខ្លួននិងកូនឡើយ ដែលជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនា មិនអាចរស់នៅជាមួយចុងចម្លើយតទៅទៀតបានឡើយ ។

៣-ចំណុចដែលវិវាទ៖

-ដើមចោទនៅតែប្តឹងទាមទារ ដូចមានក្នុងពាក្យបណ្តឹងរបស់ខ្លួនដដែល ។

**សំអាងហេតុ៖**

-តាមសេចក្តីថ្លែងការណ៍របស់លោកស្រី [redacted] ម៉ាឡា ជាដើមចោទ បានបញ្ជាក់ថា ខ្លួនប្តឹងសុំលែងលះពីចុងចម្លើយដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ដោយសំអាងហេតុថា ខ្លួននិងចុងចម្លើយបានរៀបការតាមប្រពៃណីកាលពីអំឡុងឆ្នាំ១៩៩១ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ តាមច្បាប់ ។ ដោយខ្លួន និងប្តីរស់នៅមិនចុះសម្រុងគ្នា ហើយប្តីរបស់ខ្លួនបានផិតក្បត់ទៅរស់នៅជាមួយស្រី ពុំបានផ្តល់ប្រាក់ផ្គត់ផ្គង់ដល់គ្រួសារ ជាហេតុធ្វើអោយខ្លួនអស់មនោសញ្ចេតនា ពុំអាចរស់នៅជាមួយគ្នាតទៅអនាគតបាន។ ការរួមរស់ជាមួយគ្នាកន្លងមក ខ្លួននិងចុងចម្លើយ មានកូនបីនាក់ដែលមានឈ្មោះ [redacted] ម៉ាលីន ភេទស្រី កើតនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៦,កូនទី២ឈ្មោះ[redacted] ម៉ាលីស ភេទស្រី កើតនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ និងឈ្មោះ [redacted] ដារ៉ុង ភេទប្រុស កើតនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៤ ដែលសព្វថ្ងៃកំពុងរស់នៅជាមួយខ្លួន ហើយខ្លួនសុំសិទ្ធិគ្រប់គ្រង ដោយទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូន ពីចុងចម្លើយចំនួន ៥០០.០០០រៀល (ហាសិបម៉ឺនរៀល) ក្នុង ០១ខែ (មួយខែ) ។ ខ្លួននិងចុងចម្លើយពុំមានទ្រព្យសម្បត្តិរួម និងបំណុលរួមឡើយ ។

-លោក[redacted] ដុក ជាចុងចម្លើយ មិនបានចូលខ្លួនមកឆ្លើយដោះសារ ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់នេះឡើយ ដោយគ្មានមូលហេតុ ប៉ុន្តែតុលាការបានធ្វើការជូនដំណឹងទៅចុងចម្លើយ អំពីការកោះហៅរបស់តុលាការ ត្រឹមត្រូវតាមនីតិវិធីច្បាប់រួចហើយ ។ ហេតុនេះ តុលាការ អាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និង ចេញសាលក្រមកំបាំងមុខបាន ដោយយោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-តាមសេចក្តីថ្លែងការណ៍របស់ឈ្មោះ[redacted] ម៉ាលីស និងឈ្មោះ[redacted] ដារ៉ុង ដែលជាកូន បានបញ្ជាក់ថា បើឪពុកម្តាយរបស់ខ្លួនលែងលះគ្នា ខ្លួនសុំរស់នៅជាមួយម្តាយ ជាដើមចោទ ។

-លោកស្រីមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនសុំឯកភាពតាមសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួនទាំងស្រុង និងសុំរក្សាសេចក្តីថ្លែងការណ៍របស់ខ្លួន ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ សូមឲ្យតុលាការ មេត្តាសម្រេចតាមការប្តឹងសុំរបស់កូនក្តីខ្លួន ។

-តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ១២០ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ បញ្ជាក់ថា គូភាគីពិតជាបានរៀបការជាមួយគ្នាជាប្តីប្រពន្ធ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ពិតប្រាកដមែន ។

-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ដែលបានលើកឡើងខាងលើ បញ្ជាក់ថា ការដែលខ្លួនប្តឹងសុំលែងលះពីចុងចម្លើយ ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា ដោយចុងចម្លើយមិនផ្តល់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូននិងបានផិតក្បត់មានស្រីកំណាន់ ហើយបានចុះចោលខ្លួន និងកូន ព្រមទាំងមានការប្រមាថ

មើលងាយពីស្រីកំណាន់ ម្តាយបង្កើត ប្អូនស្រីបង្កើតរបស់ប្តីខ្លួន មកលើខ្លួន និងកូនៗថែមទៀតផង ជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនា ក្នុងការរស់នៅជាមួយចុងចម្លើយតទៅទៀតហើយ ។ ការថ្លែងការណ៍នេះ មានមូលហេតុអាចឲ្យតុលាការពិចារណាបាន តាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

-ដើមចោទបានសុំសិទ្ធិគ្រប់គ្រងកូនទាំងបីនាក់ដែលមានឈ្មោះ [redacted] ម៉ាលីន ភេទស្រី កើតនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៦ , ឈ្មោះ [redacted] ម៉ាលីស ភេទស្រី កើតនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ៩៩៨ និង ឈ្មោះ [redacted] ដាំរ៉ុង ភេទប្រុស កើតនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៤ និងទាមទារសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនទាំងបីនាក់ក្នុងមួយខែចំនួន ៥០០.០០០រៀល ( ហាសិបម៉ឺនរៀល ) ។ ហេតុនេះ ដើម្បីប្រយោជន៍ដល់កូន តុលាការគប្បីសម្រេចតាមការទាមទាររបស់ដើមចោទ ព្រោះថាកូនទាំងបីនាក់របស់គូភាគី កំពុងស្ថិតក្នុងបន្ទុករបស់ដើមចោទ និងកំពុងសិក្សានៅឡើយ ហេតុនេះ ដើមចោទពិតជាមានតម្រូវការសោហ៊ុយចាំបាច់សម្រាប់ទ្រទ្រង់ជីវភាព និងការសិក្សារបស់កូន។ ចំណុចនេះ មានចែងច្បាស់ក្នុងមាត្រា ១០៣៧ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ បានបញ្ជាក់ថា ខ្លួនពុំមានទ្រព្យសម្បត្តិរួម និង បំណុលរួម ដែលត្រូវប្តឹងសុំអោយតុលាការ សម្រេចឡើយ ។

-យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តី គប្បីជាបន្ទុករបស់ចុងចម្លើយ ។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១.ឲ្យដើមចោទឈ្មោះ [redacted] **ម៉ាឡា** លែងលះពីចុងចម្លើយឈ្មោះ [redacted] **ដុក** ចាប់ពីពេលនេះតទៅ ។

២.ប្រគល់សិទ្ធិ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] ម៉ាលីន ភេទស្រី , ឈ្មោះ [redacted] ម៉ាលីស ភេទស្រី និង ឈ្មោះ [redacted] ដាំរ៉ុង ភេទប្រុស ឲ្យទៅដើមចោទឈ្មោះ [redacted] ម៉ាឡា ។

គូភាគី ត្រូវបង្កលក្ខណៈងាយស្រួលដល់គ្នាទៅវិញទៅមក ក្នុងការផ្តត់ផ្គង់ ការសួរសុខទុក្ខ និង ការប្រាស័យទាក់ទងជាមួយកូនតាមច្បាប់ ។

៣.ឲ្យចុងចម្លើយឈ្មោះ [redacted] **ជាន់** ផ្តល់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនទាំងបីនាក់ ក្នុង ០១ខែ (មួយខែ) ចំនួន ៥០០.០០០រៀល (ហាសិបម៉ឺនរៀល) ឲ្យទៅឈ្មោះ [redacted] ម៉ាឡា ជាដើមចោទ ។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ ចំពោះមុខដើមចោទ កំបាំងចុងចម្លើយ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

**ហត្ថលេខា និង ត្រា** [redacted]

........................................................................................................................................................

**បានឃើញ**

**ប្រធានសាលាដំបូង**

[redacted]

- បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម -

ថ្ងៃព្រហស្បតិ៍ ១រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

តាកែវ , ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner